អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងបាត់ខ្លួននៅក្នុងទឹក**

**វិទ្យាសាស្រ្ត** ៖ ការរស់នៅប្រចាំថ្ងៃ៖ ការស្វែងយល់និងការសង្កេត៖

**គោលបំណង**

**វិទ្យាសាស្រ្ត** ៖ វិជ្ជាសម្បទា៖

ពិសោធន៍និងស្វែងយល់ដោយប្រើប្រាស់សម្ភារផ្សេងៗនៅក្នុងការលេងដូចជា៖ លិច អណ្តែត ជ្រាបទឹក និងមិនជ្រាបទឹក វត្ថុរលាយនិងមិនរលាយ ការលាយពណ៌ បណ្តុះគ្រាប់ធញ្ញជាតិ ខ្យល់ជាដើម...។

**កម្រិតសិក្សា** ៖ មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ឡាំងទឹក ដបទឹក ក្រដាសរូបភាពមនុស្សឬសត្វផ្សេងៗ (ដែលរូបភាពផ្សេងៗអាចទាញយកក្នុងគេហទំព័ររបស់យើងបាន Rermork.org)

**ការរៀបចំ** ៖ គ្រូត្រូវរៀបចំសម្ភារដែលបានរៀបរាប់ខាងលើឱ្យបានគ្រប់គ្រាន់ មុននឹងចាប់ផ្តើមលេងល្បែងនេះ

ជៀសវាងកុំឱ្យមានការខ្វះខាតនិងភ្លេចសម្ភារអ្វីមួយនៅពេលកំពុងលេង។

**សេចក្តីណែនាំ** ៖

1. គ្រូត្រូវនិយាយនិងពន្យល់នែនាំឱ្យបានច្បាស់មុនពេលធ្វើការពិសោធន៍មួយនេះ។

2. ដំបូងត្រូវកាត់រូបភាពដែលបានបោះពុម្ពចេញមកជាមុនសិន



3. ដាក់រូបភាពដែលបានកាត់រួចចូលទៅក្នុងដបថ្លាមួយ និងគ្របគម្របវាឱ្យជិត។
4. ចាក់ទឹកចូលឡាំង ឱ្យជិតពេញ (គួរតែប្រើឡាំងពណ៌ខ្មៅ ល្អជាងពណ៌ផ្សេងៗ ព្រោះវាងាយស្រួលក្នុងការមើលឃើញច្បាស់។



5. បន្ទាប់មក សង្កត់ដបទឹកដែលមានរូបភាពនៅខាងក្នុងចូលទៅក្នុងទឹក រហូតដល់មើលរូបភាពក្នុងដបនោះលែងឃើញជាការស្រេច។



6. ពិសោធន៍បែបនេះឱ្យកុមារមើលម្តងហើយម្តងទៀតៗ និងអាចឱ្យកុមារឡើងទៅសាកល្បងលេងម្តងម្នាក់ៗបានផងដែរ។

**ប្រាប់បានពីការពិសោធន៍ថា ហេតុអ្វីបានជារូបភាពអាចបាត់ខ្លួននៅក្នុងឡាំងទឹកបែបហ្នឹង?**

- ➔ ពន្លឺជាទូទៅធ្វើដំណើរពីវត្ថុមកកាន់ភ្នែករបស់យើង។ នៅក្នុងទឹក ពន្លឺអាចចាំងចុះឡើងខាងក្នុងដូចជាកញ្ចក់អ៊ីចឹង។
- ➔ ដោយសារតែពន្លឺមិនបានមកដល់ភ្នែករបស់យើង ទើបធ្វើឱ្យដបនោះមើលមិនឃើញ!។

**វិធីងាយៗដើម្បីស្រមៃ៖**

ពន្លឺគឺដូចជាបាល់តូចៗដែលផ្ទុកនូវអ្វីដែលយើងមើលឃើញ។ ពេលខ្លះ បាល់ទាំងនោះលោតផ្លោះនៅខាងក្នុងទឹកជំនួសឱ្យការចេញមកក្រៅ។ ពេលនោះភ្នែករបស់យើងមិនអាចមើលឃើញវត្ថុនោះទេ ដូច្នេះវាហាក់ដូចជាបាត់ខ្លួន!